# គោលនយោបាយ យុទ្ធសាស្ត្រ
# និង គោលការណ៍ណែនាំ
## ស្តីពី
## ការផ្តល់ប្រឹក្សា និងការធ្វើតេស្តរកមេរោគអេដស៍
## នៅព្រះរាជាណាចក្រកម្ពុជា

**បោះពុម្ពលើកទី២ ខែកញ្ញា ឆ្នាំ២០០៤**

**ចំនួន ២,០០០ ច្បាប់**

**ក្រសួងសុខាភិបាល**

**មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ**

# គោលនយោបាយ យុទ្ធសាស្ត្រ និង គោលការណ៍ណែនាំ
# ស្តីពី
# ការផ្តល់ប្រឹក្សា និងការធ្វើតេស្តរកមេរោគអេដស៍
# នៅព្រះរាជាណាចក្រកម្ពុជា

## ១. ប្រវត្តិ

គោលនយោបាយជាតិស្តីពីការបង្ការ និងថែទាំព្យាបាលជំងឺអេដស៍ និង ជំងឺកាមរោគ របស់ក្រសួងសុខាភិបាលនៅប្រទេសកម្ពុជាបានចែងថា ក្រសួងសុខាភិបាល នឹងពង្រឹង និងគាំទ្រដល់ការពង្រីកសេវាផ្តល់ប្រឹក្សា និង សេវាធ្វើតេស្តរកមេរោគអេដស៍នៅក្នុងផ្នែកសុខាភិបាលសាធារណៈ ។ គោលនយោបាយ និងគោលការណ៍ណែនាំស្តីពីការផ្តល់ប្រឹក្សា និងធ្វើតេស្តរកមេរោគអេដស៍ បាន អនុម័តដោយក្រសួងសុខាភិបាល តាំងពីឆ្នាំ១៩៩៥ ។ យោងទៅលើការកើនឡើងនូវតំរូវការចាំបាច់នៃសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តរកមេរោគអេដស៍ និងការ ជឿនលឿនផ្នែកប្រតិកររកមេរោគអេដស៍ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បានរៀបចំកែសំរួលគោលនយោបាយ និងគោលការណ៍ណែនាំនេះនៅខែកញ្ញាឆ្នាំ ២០០១ ។ ក្រសួងសុខាភិបាលទទួលខុសត្រូវក្នុងការពង្រឹងការអនុវត្តគោលនយោបាយ គោលការណ៍ណែនាំ និងពិធីសារធ្វើតេស្តរកមេរោគអេដស៍ នៅក្នុងសេវាសាធារណៈ និងឯកជនតាមរយៈការបង្កើតប្រព័ន្ធ





- Serum that is **reactive on both tests** is considered HIV antibody **positive**.
- Serum that is reactive on the first test, but non-reactive on the second test, must be re-tested with the two assays, on the same serum sample.
- **Concordant** results after repeat testing will indicate a positive or negative result.
- If the results of the tests remain discordant the serum is considered indeterminate, and a new sample can be taken and the testing procedure repeated.

*4.4.5.2 Quality control*

NCHADS/MoH has the responsibility to ensure quality control for all HIV testing services in both the private and public sector.

*4.4.5.3 Recommended rapid tests*

Simple/rapid tests are recognised by the Ministry of Health in Cambodia as acceptable, based on WHO recommendations.

Phnom Penh,………………2002

Senior Minister and Minister of Health

- Discussion of the implications of the test result for the client
- Discussion of the client's worries and fears
- Counselling on how to deal with immediate, practical problems
- Counselling on living and coping with HIV
- Information on how to stay healthy
- Information on medical/counselling/support services, support groups, and other resources available to the client.

### *4.4.4 Supportive counselling*

Post-test counselling for a positive result can involve a series of separate counselling sessions. This supportive counselling is very important to help a client cope with his/her situation.

### *4.4.5 Testing protocol*

*4.4.5.1 Testing protocol*

The same testing protocol is used in Cambodia for testing and counselling services, and for diagnostic purposes in health institutions. This protocol is as laid down and up-dated from time to time by the Ministry of Health in these Guidelines for HIV/AIDS Counselling and Testing".

All serum/plasma is first tested with a simple/rapid assay.

- Serum that is **non-reactive on the first test** is considered HIV antibody **negative**.
- Serum found reactive on the first assay is re-tested with another rapid assay or ELISA.





ត្រួតពិនិត្យ តាមដាន និងអភិបាលលើសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តរកមេរោគអេដស៍ ។

ការផ្តល់ប្រឹក្សា និងការធ្វើតេស្តរកមេរោគអេដស៍ គឺជាផ្នែកមួយយ៉ាងសំខាន់ក្នុងយុទ្ធសាស្ត្របង្ការ និងថែទាំព្យាបាលជំងឺអេដស៍ ឈរលើហេតុផលជាច្រើនយ៉ាងដូចខាងក្រោមៈ

- ❖ សេវាផ្តល់ប្រឹក្សានិងធ្វើតេស្តរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត អាចកាត់បន្ថយការចំលងមេរោគអេដស៍គួរអោយកត់សំគាល់ តាមរយៈការបន្ថយការប្រព្រឹត្តរួមភេទប្រឈមមុខនឹងគ្រោះថ្នាក់ ។ បុគ្គលដែលដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន និង បន្ទាប់ពីបានទទួលការផ្តល់ប្រឹក្សាត្រឹមត្រូវរួចមក ទំនងជាមិនបណ្តែតបណ្តោយឱ្យមានការរួមភេទ ដែលគ្មានសុវត្ថិភាពជាមួយដៃគូច្រើនតទៅទៀតឡើយ ។
- ❖ ការផ្តល់ប្រឹក្សា និងការធ្វើតេស្តរកមេរោគអេដស៍ អាចជួយបុគ្គលទាំងឡាយអោយទទួលបាននូវសេវាវេជ្ជសាស្ត្រ និងសេវាសង្គមបានសមស្រប ។ បុគ្គលដែលបានយល់ដឹងពីការវិវត្តបែបធម្មជាតិនៃមេរោគអេដស៍ និងផលប៉ះពាល់របស់វាទៅលើសុខភាព និងជីវិតអាចជ្រើសរើសការថែទាំបែបវេជ្ជសាស្ត្របានល្អប្រសើរ ។
- ❖ ការផ្តល់ប្រឹក្សា គឺជាផ្នែកមួយយ៉ាងសំខាន់នៃសេវាចិត្តសាស្ត្រសង្គម និងបានចាត់ទុកថា ជាផ្នែកមួយនៃកម្មវិធីថែទាំអ្នកជំងឺតាមផ្ទះ ិងក្នុងហាគមន៏ ដែលត្រូវផ្តល់អោយអ្នកជំងឺ ក៏ដូចជាការថែទាំ ក្នុងមន្ទីរពេទ្យ និងក្នុងមណ្ឌលថែទាំអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍អនាថាផងដែរ ។

- ❖ ការធ្វើតេស្តរកមេរោគអេដស៍ គឺជាមធ្យោបាយមួយយ៉ាងសំខាន់សំរាប់ធ្វើរោគវិនិច្ឆ័យដែលជា ជំនួយដល់ការថែទាំព្យាបាលក្នុងមន្ទីរពេទ្យ និងតាមគ្លីនិក ។
- ❖ ការធ្វើតេស្តរកមេរោគអេដស៍ និងការផ្តល់ប្រឹក្សាមាន សារៈសំខាន់ជាពិសេស ចំពោះកម្មវិធីបង្ការ ការចំលងមេរោគអេដស៍ពីម្តាយទៅទារក ។ ស្ត្រីមានផ្ទៃពោះត្រូវយល់ដឹងអំពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន ដើម្បីទទួលបាននូវអត្ថប្រយោជន៍ពេញលេញពីកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅទារក ។
- ❖ ការធ្វើតេស្តរកមេរោគអេដស៍ គឺជាផ្នែកមួយយ៉ាងសំខាន់សំរាប់ប្រព័ន្ធនៃការអង្កេតឃ្លាំមើល និងការស្រាវជ្រាវ [១] ។
- ❖ ក៏ប៉ុន្តែទំរង់បែបបទនៃការធ្វើតេស្តនិងផ្តល់ប្រឹក្សាទាំងអស់នេះ ទាមទារឱ្យមានការយកចិត្តទុកដាក់ជាពិសេស ចំពោះក្រមសីលធម៌នៃជំងឺអេដស៍ និងកាមរោគ និងការធានាពីគុណភាពនៃការធ្វើតេស្ត ។ ការរក្សាការសំងាត់ក្នុងការផ្តល់ប្រឹក្សា និង ការធ្វើតេស្តរកមេរោគអេដស៍មានសារៈសំខាន់ណាស់ ។ សេចក្តីមេត្តាករុណា គឺជាមូលដ្ឋានគ្រឹះនៃការផ្តល់ប្រឹក្សា ។

*(១) ចំណាំថាការធ្វើតេស្តសំរាប់ផ្តល់ឈាមគឺជាការទទួលខុសត្រូវរបស់មជ្ឈមណ្ឌលជាតិផ្តល់ឈាម*

បណ្តាញការងារសំរាប់សេវាធ្វើតេស្តរកមេរោគអេដស៍ និង ផ្តល់ប្រឹក្សាបានបង្កើតរួចជាស្រេចនៅក្នុងប្រទេសកម្ពុជា ។ សេវាធ្វើតេស្តរកមេរោគអេដស៍និងផ្តល់ប្រឹក្សាដំបូងបង្អស់ បានបង្កើតឡើងក្នុងឆ្នាំ១៩៩៥ នៅវិទ្យាស្ថានប៉ាស្ទ័រ កម្ពុជា ដែលមានសេវាមន្ទីរពិសោធន៍ឯកទេសរកមេរោគអេដស៍ ។ ឆ្នាំបន្តបន្ទាប់ មកទៀត





- Discussion of the client's best options and plans for risk reduction
- Explanation of the meaning and implications of negative and positive test results, including explanation of the "window period".

### *4.4.3 Post-test counselling*

Post-test counselling should be provided when the client returns to get their test results. Informing clients of their test results by telephone or letter, or without post-test counselling, is strictly prohibited.

Post-test counselling should cover:

*With negative results:*

- Notification of the test result and discussion of its meaning and implications
- Discussion of the test result and summary of the client's plans for risk reduction, with psychological support from the counsellor
- Planning for a further test as appropriate.

*With positive results:*

- Notification of the test result and its meaning
- Reassurance that the client can learn to cope with his/her situation
- Discussion of client's feelings and emotions
- Emotional and psychological support

- Testing procedures must conform to the protocols laid out in these guidelines (Section 4.4.5 below), or as amended by the Ministry of Health from time to time.
- They must maintain strict confidentiality of all test results.

### *4.4.1 Procedures for ensuring confidentiality*

- Privacy for the counsellor and client should be ensured to the extent possible.
- A bulletin sheet with a code number should be started for the client by the counsellor.
- Blood samples should be taken in a different place; the blood sample and bulletin sheet are then sent to the laboratory.
- After testing, laboratory staff record the test result on the bulletin sheet and place it inside an envelope with only the code number written on it; the envelope is then returned to the counsellor, who gives it to the client.
- The client opens the envelope, unless he/she specifically asks the counsellor to.

### *4.4.2 Pre-test counselling*

Pre-test counselling should cover:

- Discussion of the reasons for requesting testing services
- Assessment of the client's understanding of HIV/AIDS information
- Assessment and discussion of the client's HIV risk





សេវាធ្វើតេស្តនិងផ្តល់ប្រឹក្សាដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ចំនួន ប្រាំបានបង្កើតបន្ថែមទៀត : នៅភ្នំពេញមានសេវាធ្វើតេស្តរកមេរោគអេដស៍ ចំនួនពីរ (មួយនៅក្នុងគ្លីនិកជាតិសើស្បែក និងកាមរោគ និងមួយទៀតនៅក្នុងមន្ទីរពេទ្យព្រះបាទនរោត្តមសីហនុ) នៅខេត្តបាត់ដំបងមានមួយ នៅខេត្តកំពង់ចាម មានមួយ និងមួយទៀតនៅខេត្តសៀមរាប ។ ក្នុងឆ្នាំ ១៩៩៩ សេវាទី៧ បានបង្កើតឡើងនៅក្រុងព្រះសីហនុ ។ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ សង្ឃឹមថានឹងពង្រីកសេវានេះអោយបានគ្រប់ខេត្ត-ក្រុង នៅឆ្នាំ២០០៥ ។ ការធ្វើតេស្តរកមេរោគអេដស៍ក្នុងគោលបំណងធ្វើរោគវិនិច្ឆ័យ ត្រូវបានអនុវត្តន៍នៅតាមមន្ទីរពេទ្យជាតិ និងមន្ទីរពេទ្យបង្អែក (ថ្នាក់ខេត្ត-ក្រុង) មួយចំនួន ។ អង្គការក្រៅរដ្ឋាភិបាលមួយចំនួននៅភ្នំពេញ ក៏ដូចជាតាមបណ្តាខេត្ត បានផ្តល់សេវាផ្តល់ប្រឹក្សាមុន និងក្រោយពេលធ្វើតេស្ត និងផ្តល់សេវាធ្វើតេស្តរកមេរោគអេដស៍ ។ ជារួមសេវាដែលមាននាពេលបច្ចុប្បន្ននេះបានគ្របដណ្តប់ចំពោះអ្នកត្រូវការ បានតែមួយចំនួនតូចប៉ុណ្ណោះ ។ ក្នុងពេលជាមួយគ្នានេះដែរ មានសេវាធ្វើតេស្តរកមេរោគអេដស៍ឯកជនដែលគ្មានច្បាប់អនុញ្ញាតជាច្រើន បានដំណើរការនៅក្នុងក្រុងធំៗមួយចំនួន ដោយមានទំនាក់ទំនងជាមួយមន្ទីរពេទ្យ និងគ្លីនិកឯកជនហើយបានដំណើរការដោយឯករាជ្យ ។

### ១.១. : គោលបំណង

១.១.១ ដើម្បីពង្រីង និងគាំទ្រដល់ការពង្រីក និង បន្តសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តរកមេរោគអេដស៍ ក្នុងផ្នែកសុខភាពសាធារណៈ ។

១.១.២ ដើម្បីធានាថា គោលនយោបាយ គោលការណ៍ណែនាំ និងពិធីសារសំរាប់ធ្វើតេស្តរកមេរោគអេដស៍ និងផ្តល់ប្រឹក្សា បានអនុវត្តន៍ត្រឹមត្រូវ

ក្នុងសេវាសុខភាពសាធារណៈ និងឯកជនតាមរយៈការបង្កើតប្រព័ន្ធត្រួតពិនិត្យតាមដាន និង អភិបាលដ៏សមស្រប ។

១.១.៣ ដើម្បីធានានូវគុណភាពនៃសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តរកមេរោគអេដស៍ក្នុងប្រទេសកម្ពុជា ។

១.១.៤ ដើម្បីធានាថាអ្នកដែលត្រូវការសេវាធ្វើតេស្តរកមេរោគអេដស៍ និង ផ្តល់ប្រឹក្សាមានលទ្ធភាពក្នុងការប្រើប្រាស់ និងទទួលការលើកទឹកចិត្តអោយប្រើប្រាស់ ។

## ២. គោលនយោបាយសំរាប់ធ្វើតេស្តរកមេរោគអេដស៍

២.១ ក្នុងកាលៈទេសៈណាក៏ដោយ ការធ្វើតេស្តរកមេរោគអេដស៍ដោយ ចាប់បង្ខំ* (mandatory testing) ត្រូវហាមឃាត់ជាដាច់ខាតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២.២ ក្នុងកាលៈទេសៈណាក៏ដោយ ការតំរូវអោយធ្វើតេស្តរកមេរោគអេដស៍ ** (Compulsory testing) ត្រូវហាមឃាត់លើកលែងតែមានតំរូវការតាមផ្លូវច្បាប់ ។

២.៣ រាល់ការធ្វើតេស្តរកមេរោគអេដស៍ ត្រូវអនុវត្តដោយស្ម័គ្រចិត្ត និងមានការយល់ព្រមពីអតិថិជន ។

២.៤ រាល់ការធ្វើតេស្តរកមេរោគអេដស៍អនាមិក (anonymous, unlinked testing) ក្នុងគោលបំណងស្រាវជ្រាវ ឬ អង្កេត ត្រូវសុំការអនុញ្ញាតិពីគណៈកម្មការក្រមសីលធម៌ និង ក្រសួងសុខាភិបាលជាមុន ហើយត្រូវអនុវត្ត



គោលនយោបាយ យុទ្ធសាស្ត្រ និងគោលការណ៍ណែនាំស្តីពីការផ្តល់ប្រឹក្សានិងការធ្វើតេស្តរកមេរោគអេដស៍

### 4.3 Diagnostic testing in public and private health care facilities

- HIV testing for diagnostic purposes should only be carried out where confirmation of the patient's HIV status would clearly benefit the patient in terms of determining of the best course of treatment, and with the full informed consent of the patient.
- Minors should only be tested with the permission of their parents or their legal guardians with appropriate pre- test counselling.
- Pre-test counselling should be provided as part of informed consent; the patient should be informed of the results of testing only with post-test counselling, and only at the request of the patient.
- Test results must be kept strictly confidential and confined to staff directly responsible for the patient's medical care.
- No relative of the patient should be notified of the test or of the result, unless the patient has given explicit permission.

### 4.4 Testing within voluntary counselling and testing services

All voluntary counselling and testing services, whether in the public or private sector, must conform to the following standards:

- They must be licensed by the Ministry of Health
- They should provide testing services only to people who request these services
- All testing must be accompanied by pre- and post-test counselling as laid down in these guidelines.
- Counselling and laboratory staff must be qualified according to Ministry of Health standards

Data from testing services occurring in health establishments in both the public and private sectors will be monitored by NCHADS, who will establish a data-base and reporting and monitoring system.

### *3.1.5 Support groups for referral*

Since there are more people being tested for HIV and a growing number of people living with HIV/AIDS, self-help groups for PLWHA and other community based organisations working with PLWHA should be supported.

### *2.1.6 Operational research*

Much needs still to be learned about HIV counselling and testing in Cambodia in order to improve the provision of these services suitable for the Cambodian situation.

## 4. GUIDELINES FOR ESTABLISHING COUNSELLING ANDS TESTING SERVICES

### 4.1 Purpose of Testing

HIV testing is allowed in the following situations:

- Surveillance within the Ministry of Health Surveillance Programme
- Diagnostic purposes (within institutional settings)
- Voluntary counselling and testing services
- Research

### 4.2 Surveillance

- Refer to the **Protocols** and **Strategy for Surveillance of HIV/AIDS and STI and Related Behaviour** of the Ministry of Health.



គោលនយោបាយ យុទ្ធសាស្រ្ត និងគោលការណ៍ណែនាំស្តីពីការផ្តល់ប្រឹក្សានិងការធ្វើតេស្តរកមេរោគអេដស៍

ទៅតាមគោលការណ៍ណែនាំស្តីពីក្រមសីលធមិសំរាប់ការស្រាវជ្រាវជំងឺអេដស៍ និងជំងឺកាមរោគ ដែលបានអនុម័តដោយក្រសួងសុខាភិបាល ។

២.៥ ស្ថាប័នរដ្ឋ និងឯកជន ដែលដំណើរការធ្វើតេស្តរកមេរោគអេដស៍ ដោយស្ម័គ្រចិត្តត្រូវគោរពអោយបានម៉ឺងម៉ាត់ទៅតាមគោលនយោបាយ និងគោលការណ៍ណែនាំស្តីពីការធ្វើតេស្តរកមេរោគអេដស៍ ចែងដោយក្រសួងសុខាភិបាល ។ ស្ថាប័នទាំងអស់ត្រូវធ្វើការផ្តល់ប្រឹក្សាមុន និងក្រោយពេលធ្វើតេស្ត និងផ្តល់លទ្ធផលដែលធានាថាត្រឹមត្រូវ ។ ស្ថាប័នទាំងអស់ត្រូវមានការអនុញ្ញាតិ និងត្រួតពិនិត្យដោយក្រសួងសុខាភិបាល និងត្រូវតែមាន បុគ្គលិកដែលបានទទួលការបណ្តុះបណ្តាលក្នុងវគ្គសិក្សា ដែលអនុម័តដោយក្រសួងសុខាភិបាល ។

* *ការធ្វើតេស្តរកមេរោគអេដស៍ដោយចាប់បង្ខំសំដៅដល់ការធ្វើតេស្តទាំងឡាយណាដែលអតិថិជនពុំមានជំរើសក្នុងការបដិសេធ ។*

** *ការតំរូវអោយធ្វើតេស្ត សំដៅដល់ការធ្វើតេស្តទាំងឡាយណាដែលទទួលបានផលប្រយោជន៍ពីសេវាពិសេសណាមួយ ឧទាហរណ៍ៈដើម្បីសុំទិដ្ឋិការ រកការងារ ថែទាំសុខភាព ។ ល ។ ប៉ុន្តែអតិថិជនមានជំរើសក្នុងការបដិសេធចំពោះផលប្រយោជន៍ពីសេវាទាំងនោះ ដោយមិនទទួលយកការធ្វើតេស្ត*

២.៦ រាល់សេវាធ្វើតេស្តរកមេរោគអេដស៍ និង ផ្តល់ប្រឹក្សាស្តីពីជំងឺអេដស៍ទាំងសាធារណៈ និងឯកជនត្រូវផ្តល់របាយការណ៍ទៅមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ នៃក្រសួងសុខាភិបាលដោយប្រើប្រាស់ទំរង់របាយការណ៍គំរូ កំណត់ដោយមជ្ឈមណ្ឌលជាតិនេះ ។

២.៧ គោលនយោបាយ យុទ្ធសាស្រ្ត និង គោលការណ៍ណែនាំស្តីពីការផ្តល់ប្រឹក្សា និងការធ្វើតេស្តរកមេរោគអេដស៍ និងការអនុវត្តន៍ ត្រូវពិនិត្យឡើងវិញរៀងរាល់ពីរឆ្នាំម្តង (អាចមានការកែសំរួលប្រសិនបើចាំបាច់) ។

# ៣. យុទ្ធសាស្ត្រស្តីពីការផ្តល់ប្រឹក្សានិងការធ្វើតេស្តរកមេរោគអេដស៍

## ៣.១. យុទ្ធសាស្ត្រ :

តាមរយៈផែនការជាតិជាយុទ្ធសាស្ត្រសំរាប់ការបង្ការ ថែទាំ និងព្យាបាលជំងឺអេដស៍ និងកាមរោគ ឆ្នាំ ២០០១-២០០៥ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ នឹងពង្រីកសេវានេះអោយបានគ្រប់ខេត្ត-ក្រុងទាំងអស់ ។

### ៣.១.១ ផ្សព្វផ្សាយគោលនយោបាយ យុទ្ធសាស្ត្រ និងគោលការណ៍ណែនាំស្តីពីការផ្តល់ប្រឹក្សា និងការធ្វើតេស្តរកមេរោគអេដស៍

ការផ្តល់ប្រឹក្សា និងការធ្វើតេស្តរកមេរោគអេដស៍ នឹងធ្វើឡើងទៅតាមស្ថានភាពមួយចំនួននៅពេលដែលមានការពង្រីកកម្មវិធីបង្ការ និងថែទាំជំងឺអេដស៍ ។ តាមរយៈសេវាធ្វើតេស្តរកមេរោគអេដស៍ និងផ្តល់ប្រឹក្សាដោយស្ម័គ្រចិត្តនិងរក្សាការសំងាត់ នៅក្នុងសេវាថែទាំសុខភាពក្នុងកម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅទារក និងក្នុងគ្លីនិកឯកជនផ្សេងៗ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគនឹងធានាអោយមានគំរូធ្វើតេស្ត និងធានាអោយមានសេវាដែលមានគុណភាពខ្ពស់តាមរយៈការផ្សព្វផ្សាយអោយបានទូលំទូលាយ នូវគោលនយោបាយគោលការណ៍ណែនាំស្តីពីការផ្តល់ប្រឹក្សា និងធ្វើតេស្តរកមេរោគអេដស៍ ។ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ នឹងធានាអោយមានការសហការ និងទំនាក់ទំនងគ្នារវាងសេវាផ្តល់ប្រឹក្សា និងធ្វើ





programmes, and in a variety of private sector settings. NCHADS will ensure that appropriate standards are set and maintained, and that the quality of services is suitable, through the widespread dissemination of policies and guidelines for counselling and testing. NCHADS will ensure that collaboration and linkages are established between counselling and testing services in all their settings, and the other elements of prevention and care programmes.

### *3.1.2 Expand and extend Testing and Counselling services*

To provide direct counselling and testing services, NCHADS will establish new Centres for Voluntary Testing and Counselling (VTCC) over the next few years, based on the model and experience of the present six VTCCs

### *3.1.3 Standardize and disseminate a curriculum and training materials for HIV/AIDS Counselling, and build up the capacity of personnel working in counselling and testing services.*

The training curriculum for HIV counselling will be reviewed and updated and will be used for future training. A number of organisations are building up experience with both counselling itself, and training for counselling. These experiences will be drawn upon for training curricula for counselling appropriate to Cambodian culture, experience and needs.

### *3.1.4 Support the establishment of monitoring and supervision systems for counselling and testing services*

NCHADS will review and update supervision and monitoring tools to be used together with supervision checklists for provincial health supervisors to monitor and supervise counselling and testing services in a systematic way.

2.4 All anonymous, un-linked testing conducted for research or survey purposes must have prior approval of the Ethics Committee and the Ministry of Health and be in conformity with the Ethical Guidelines for HIV/AIDS and STI related Research approved by the Ministry of Health.

2.5 All public and private institutions which conduct voluntary HIV tests must strictly follow the policy and guidelines for HIV testing laid down by the Ministry of Health. They must provide adequate pre-test and post-test counselling, and accurate results. All such institutions must be licensed and supervised by the Ministry of Health, and must be run by staff who have been trained under courses approved by the Ministry of Health.

2.6 All HIV/AIDS testing and counselling services, public and private, must report regularly to the National Centre for HIV/AIDS, Dermatology and STI/Ministry of Health using standardised reporting formats determined from time to time by NCHADS.

2.7 The policy, strategy and guidelines and their implementation will be reviewed each two years (and modification if necessary).

## 3. THE COUNSELLING AND TESTING STRATEGY

### 3.1 Strategy

Under the Strategic Plan for HIV/AIDS and STI Prevention and Care 2001-2005, NCHADS intends to expand these services nationwide.

#### *3.1.1 Disseminate the Policy, Strategy and Guidelines for HIV Counselling and for HIV Testing*

Counselling and testing will take place in a number of situations as the HIV/AIDS prevention and care programmes expand; in voluntary testing and counselling services, in health services, as part of PMTCT





តេស្តរកមេរោគអេដស៍ទៅគ្រប់ គ្រឹះស្ថានពាក់ព័ន្ធ និងកម្មវិធីបង្ការ និង ថែទាំជំងឺអេដស៍ផ្សេងៗទៀត ។

#### ៣.១.២ ពង្រីក និងបន្តសេវាធ្វើតេស្ត និងសេវាផ្តល់ប្រឹក្សា

ដើម្បីផ្តល់សេវាប្រឹក្សា និងធ្វើតេស្តរកមេរោគអេដស៍អោយបានច្រើន មជ្ឈមណ្ឌលជាតិ នឹងបង្កើតសេវាធ្វើតេស្ត និងផ្តល់ប្រឹក្សា ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ថ្មីបន្ថែមក្នុងរង្វង់ ២-៣ឆ្នាំ ខាងមុខផ្អែកលើគំរូ និង បទពិសោធន៍ ដែលទទួលបានពីសេវាធ្វើតេស្តរកមេរោគអេដស៍ដែលមាន ស្រាប់ទាំង៧ ។

#### ៣.១.៣ រៀបចំកម្មវិធីគំរូ ការផ្សព្វផ្សាយកម្មវិធីគំរូ សំភារៈបណ្តុះបណ្តាល សំរាប់ការផ្តល់ប្រឹក្សា និង បង្កើនសមត្ថភាពបុគ្គលិកសេវាផ្តល់ប្រឹក្សា និង ធ្វើតេស្តរកមេរោគអេដស៍

កម្មវិធីបណ្តុះបណ្តាលសំរាប់ផ្តល់ប្រឹក្សាស្តីពីជំងឺអេដស៍ នឹងត្រូវពិនិត្យ និង កែសំរួលឡើងវិញដើម្បី ប្រើប្រាស់ក្នុងការបណ្តុះបណ្តាលទៅថ្ងៃ អនាគត ។ អង្គការមួយចំនួនកំពុងតែបង្កើនបទពិសោធន៍ទាំងលើ ការផ្តល់ប្រឹក្សាទាំង ការបណ្តុះបណ្តាលស្តីពីការផ្តល់ប្រឹក្សា ។ បទពិសោធន៍ទាំងនេះនឹងត្រូវ ដកស្រង់ សំរាប់បង្កើតកម្មវិធីបណ្តុះបណ្តាលស្តីពីការផ្តល់ប្រឹក្សាអោយ សមស្រប ទៅតាមវប្បធមិ បទពិសោធន៍ និងតំរូវការក្នុងប្រទេសកម្ពុជា ។

### ៣.១.៤ គាំទ្រដល់ការបង្កើតប្រព័ន្ធត្រួតពិនិត្យតាមដាន និងអភិបាលកិច្ចសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តរកមេរោគអេដស៍ :

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ នឹងធ្វើការពិចារណាកែសំរួល នូវការប្រើប្រាស់ឧបករណ៍សំរាប់តាមដាន និងអភិបាល និងរៀបចំបង្កើតជាបញ្ជីត្រួតពិនិត្យសំរាប់អ្នកអភិបាល ថ្នាក់ខេត្តផងដែរដើម្បីត្រួតពិនិត្យតាមដាន និងអភិបាលសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តអោយក្លាយទៅជារបព័ន្ធទិន្នន័យដែលបានពីសេវាធ្វើតេស្តរកមេរោគអេដស៍ ក្នុងសេវាសុខាភិបាលសាធារណៈ និងឯកជននឹងត្រូវត្រួត ពិនិត្យតាមដាន ដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ តាមរយៈការបង្កើតប្រព័ន្ធទិន្នន័យមូលដ្ឋាន ប្រព័ន្ធរបាយការណ៍ និងប្រព័ន្ធត្រួតពិនិត្យតាមដាន ។

### ៣.១.៥ ក្រុមគាំទ្រ សំរាប់បញ្ជូន

ដោយហេតុថា មានអតិថិជនជាច្រើនបានមកធ្វើតេស្តរកមេរោគអេដស៍ និងដោយមានការកើនឡើងនូវចំនួនអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ចាំបាច់ត្រូវជួយឧបត្ថម្ភក្រុមគាំទ្រអ្នកជំងឺអេដស៍ និងអង្គការក្នុងសហគមន៍នានាដែលធ្វើការជាមួយអ្នកជំងឺអេដស៍ ។

### ៣.១.៦ ការស្រាវជ្រាវបែបអនុវត្តន៍ (Operational research) :

ចាំបាច់ត្រូវធ្វើការសិក្សាជាច្រើនទៀតអំពីការផ្តល់ប្រឹក្សា និងការធ្វើតេស្តរកមេរោគអេដស៍នៅប្រទេសកម្ពុជា ដើម្បីលើកស្ទួយការផ្តល់សេវាទាំងនេះអោយសមស្របទៅតាមស្ថានភាពប្រទេសកម្ពុជា ។



គោលនយោបាយ យុទ្ធសាស្ត្រ និងគោលការណ៍ណែនាំស្តីពីការផ្តល់ប្រឹក្សានិងការធ្វើតេស្តរកមេរោគអេដស៍

of testing centres operating in most major towns, both linked to private hospitals ands clinics and operating independently.

## 1.1 Objectives

1.1.1 To strengthen and support the expansion and extension of HIV counselling and testing services in the public health sector.

1.1.2 To ensure that the Policy, Guidelines and Protocols for Testing and Counselling are observed in public and private health services through the establishment of monitoring and supervision systems for counselling and testing services.

1.1.3 To ensure the quality of HIV counselling and testing in Cambodia.

1.1.4 To ensure those who need VCT have accessed to VCT services and are encouraged to use them.

## 2. POLICY FOR HIV TESTING

2.1 Mandatory* testing for HIV under any circumstances is prohibited in the Kingdom of Cambodia.

2.2 Compulsory* testing for HIV under any circumstances is also prohibited, unless required by law.

2.3 All testing for HIV should be full and informed agreement of the person being tested.

* Mandatory testing refers to testing that is conducted without any option for refusal. Compulsory testing refers to testing which is required in order to access a particular benefit or service (eg visa, employment, medical care, etc) but where the subject has the option of rejecting the service or benefit and thus avoiding the test.

- Counselling is an important part of the psychosocial services offered as part of home and community care programmes, as well as institutional and hospice care.

- Testing and counselling are particularly important in PMTCT programmes. Pregnant women need to know and understand their HIV status so that they can take full benefit from the PMTCT services offered.

- Testing is an important diagnostic tool in providing effective institutional and clinical care.

- Testing is an essential part of the sero-surveillance system and research[1].

But all these forms of testing and counselling demand special attention to the ethics of HIV/AIDS and quality assurance. Confidentiality in all counselling and testing is very important. Compassion is at the root of all counselling.

A network of HIV testing and counselling centres already exist in Cambodia. In 1995 the first testing and counselling centre was established at the Pasteur Institute of Cambodia, which has a specialised HIV laboratory service. Over the next year five further voluntary testing and counselling centres (VTCC) were established: two in Phnom Penh (at the National STI Clinic and Preah Bat Norodom Sihanouk Hospital), and in Battambang, Kampong Cham and Siem Reap. In 1999 a seventh was added in Sihanoukville. NCHADS expects to have a VTCC in each province throughout the country by the year 2005.
Testing for diagnostic purposes is conducted at all National and some Referral Hospitals at Provincial level. A number of NGOs provide pre- and post-test counselling and testing services, both in Phnom Penh and in the provinces. These services, however, presently reach only a small proportion of those who might need them. At the same time, a large and unregulated private network

[1] Note that testing for blood screening is the responsibility of the National Blood Transfusion Centre





# ៤. គោលការណ៍ណែនាំស្តីពីការបង្កើតសេវាផ្តល់ប្រឹក្សា និងការធ្វើតេស្តរកមេរោគអេដស៍

## ៤.១ គោលបំណងនៃការធ្វើតេស្ត:

ការធ្វើតេស្តរកមេរោគអេដស៍ ទទួលបានការអនុញ្ញាតិនៅក្នុងស្ថានភាព ដូចខាងក្រោម :

- *ការអង្កេតរកមេរោគអេដស៍នៅក្នុងកម្មវិធីអង្កេត របស់ក្រសួងសុខាភិបាល*
- *គោលបំណងធ្វើរោគវិនិច្ឆ័យ (នៅក្នុងគ្រឹះស្ថានព្យាបាលនានា)*
- *សេវាផ្តល់ប្រឹក្សា និងធ្វើតេស្តរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់*
- *ការស្រាវជ្រាវ*

## ៤.២ ការអង្កេតស្រាវជ្រាវ

យោងតាមពិធីសារ និងយុទ្ធសាស្ត្ររបស់ក្រសួងសុខាភិបាលស្តីពីការអង្កេតរកមេរោគអេដស៍ និង កាមរោគ និងការផ្លាស់ប្តូរការប្រព្រឹត្ត ។

## ៤.៣ ការធ្វើតេស្តរកមេរោគអេដស៍ សំរាប់ធ្វើរោគវិនិច្ឆ័យក្នុងគ្រឹះស្ថានថែទាំ

**សុខភាព សាធារណៈ និងឯកជន**

- ❖ ការធ្វើតេស្តរកមេរោគអេដស៍ក្នុងគោលបំណងធ្វើរោគវិនិច្ឆ័យ គួរតែអនុវត្តន៏នៅកន្លែងណាដែល ក្រោយពីបានដឹងនូវស្ថានភាពផ្ទុកមេរោគអេដស៍ អ្នកជំងឺអេដស៍អាចទទួលបាននូវការថែទាំព្យាបាល ឬការបញ្ជូនទៅរកការព្យាបាលមួយដ៏ប្រសើរ និងមានការយល់ព្រមជាមុនពីអ្នកជំងឺ ។

- ❖ ចំពោះអ្នកមានអាយុក្រោម ១៨ឆ្នាំ ការធ្វើតេស្តរកមេរោគអេដស៍ត្រូវសុំអនុញ្ញាតិពីឳពុកម្តាយ ឬ អាណាព្យាបាលជាមុនដោយមានការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តអោយបានត្រឹមត្រូវ ។

- ❖ ត្រូវផ្តល់ការប្រឹក្សាមុនពេលធ្វើតេស្ត ដើម្បីឱ្យមានការយល់ព្រមជាមុនពីអ្នកជំងឺ ។ ការផ្តល់លទ្ធផលតេស្ត ត្រូវមានការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្ត ។ ហើយធ្វើទៅបានលុះណាតែមានសំណូមពរពីអ្នកជំងឺប៉ុណ្ណោះ ។

- ❖ លទ្ធផលតេស្ត ត្រូវតែរក្សាទុកជាការសំងាត់អោយបានហ្មត់ចត់ និងអាចដឹងបានត្រឹមបុគ្គលិកទទួល បន្ទុកការថែទាំអ្នកជំងឺប៉ុណ្ណោះ ។
- ❖ គ្មានសមាជិកគ្រួសារអ្នកជំងឺណាម្នាក់ ត្រូវទទួលដំណឹងអំពីការធ្វើតេស្តឬលទ្ធផលតេស្តឡើយ លើកលែងតែមានការអនុញ្ញាតិពីអ្នកជំងឺ ។

**៤.៤ ការធ្វើតេស្តរកមេរោគអេដស៍ នៅក្នុងសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់**





# POLICY, STRATEGY AND GUIDELINES FOR HIV/AIDS COUNSELLING AND TESTING

## 1. Background

The Policy for HIV/AIDS and STI Prevention and Care in the health sector in Cambodia lays down that the Ministry of Health will strengthen and support the expansion and extension of HIV counselling and testing services in the public health sector. The policy and strategy for HIV/AID Counselling and Testing have approved by Ministry of Health in 1995. In response to the increasing need for counselling and testing services and the progress of HIV reagents, the National Center for HIV/AIDS Dermatology and STD has reviewed and revised this policy and strategy in September 2001. The Ministry of Health also has the responsibility to enforce the Policy, Guidelines and Protocols for Testing and Counselling in public and private health services through the establishment of monitoring and supervision systems for counselling and testing services.

Counselling and Testing are important parts of the overall HIV/AIDS prevention and care strategy for several reasons, and in several forms:

- Voluntary counselling and testing services can significantly reduce HIV transmission by reducing sexual risk behaviour. People who know their HIV status after good counselling are less likely to indulge in unprotected sex with multiple partners.

- Counselling and testing can help people access appropriate medical and social services. People who understand the nature of HIV infection and its effects on their health and life can make better choices about the kinds of medical care they choose.

### ៤.៤.៥.៣ តេស្តរហ័ស (Rapid test ) ដែលប្រើប្រាស់

តេស្តធម្មតា រឺតេស្តរហ័សដែលប្រើប្រាស់ត្រូវទទួលស្គាល់ និងយល់ព្រម ដោយក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា យោងតាមគំរូរបស់ អង្គការសុខភាពពិភពលោក (WHO) .

ភ្នំពេញថ្ងៃទី ខែ ឆ្នាំ២០០២

**ទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសុខាភិបាល**



គោលនយោបាយ យុទ្ធសាស្ត្រ និងគោលការណ៍ណែនាំស្តីពីការផ្តល់ប្រឹក្សានិងការធ្វើតេស្តរកមេរោគអេដស៍

ទោះជានៅក្នុងស្ថាប័នរដ្ឋ រឺឯកជនក៏ដោយ រាល់សេវាផ្តល់ប្រឹក្សានិងធ្វើតេស្តរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត ត្រូវអនុវត្តន៍តាមបែបបទខាងក្រោមនេះ :

- ត្រូវមានការអនុញ្ញាតិពីក្រសួងសុខាភិបាល
- ផ្តល់សេវាធ្វើតេស្តចំពោះអតិថិជនណាដែលស្នើសុំតែប៉ុណ្ណោះ
- រាល់ការធ្វើតេស្តរកមេរោគអេដស៍ ត្រូវតែមានការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្ត និងក្រោយពេលធ្វើតេស្ត ដូចមានចែងក្នុងគោលការណ៍ណែនាំនេះ ។
- បុគ្គលិកផ្តល់ប្រឹក្សា និងធ្វើតេស្តរកមេរោគអេដស៍ត្រូវមានសមត្ថភាពតាមខ្នាតគំរូរបស់ក្រសួងសុខាភិបាល
- បែបបទនៃការធ្វើតេស្តរកមេរោគអេដស៍ ត្រូវអនុលោមទៅតាមពិធីសារដូចមានចែងក្នុង គោលការណ៍ណែនាំនេះ (មើលផ្នែក ៤.៤.៥ ខាងក្រោម) រឺ អាចកែប្រែដោយក្រសួងសុខាភិបាល ។
- ត្រូវរក្សាការសំងាត់អោយបានខ្ជាប់ខ្ជួន រាល់លទ្ធផលតេស្តរកមេរោគអេដស៍

### ៤.៤.១ បែបបទដើម្បីធានាការរក្សាការសំងាត់

- ត្រូវធានាភាពជាឯកជនដល់អ្នកផ្តល់ប្រឹក្សា និងអតិថិជនតាមដែលអាចធ្វើទៅបាន

- ត្រូវផ្តល់ជូនប័ណ្ណវិភាគមានចុះលេខកូដសំងាត់ ដល់អតិថិជនដោយអ្នកផ្តល់ប្រឹក្សា

- ការបូមឈាមគួរប្រព្រឹត្តទៅនៅកន្លែងមួយដោយឡែក ហើយឈាម និងប័ណ្ណវិភាគត្រូវបញ្ជូនទៅមន្ទីរពិសោធន៍

- បន្ទាប់ពីការធ្វើតេស្ត បុគ្គលិកមន្ទីរពិសោធន៍ត្រូវកត់ត្រាលទ្ធផល តេស្តនៅក្នុងប័ណ្ណវិភាគ ហើយដាក់ក្នុងស្រោមសំបុត្របិទជិតចុះតែ លេខសំងាត់ប៉ុណ្ណោះ ហើយបញ្ជូនទៅអ្នកផ្តល់ប្រឹក្សាដែលត្រូវផ្តល់ជូនអតិថិជន
- អ្នកផ្តល់ប្រឹក្សាគ្មានសិទ្ធិក្នុងការបើកមើលលទ្ធផលទេ លុះណាតែមានការស្នើសុំពីអតិថិជន

## ៤.៤.២ ការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តរកមេរោគអេដស៍:

ការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តត្រូវមាន:

- ការពិភាក្សាអំពីហេតុផលដែលអតិថិជនស្នើសុំធ្វើតេស្ត





- *សេរ៉ូមឈាមប្រតិកម្មក្នុងពេលធ្វើតេស្តលើកទី១ ប៉ុន្តែមិនប្រតិកម្មក្នុងពេលធ្វើតេស្តលើកទី២ ត្រូវធ្វើតេស្តទាំងពីរនេះសារឡើងវិញដោយប្រើសេរ៉ូមឈាមដដែល ។*

- *លទ្ធផលស្របគ្នានៃការធ្វើតេស្តឡើងវិញនេះ បញ្ជាក់ពីលទ្ធផល វិជ្ជមាន រឺ អវិជ្ជមាន*

- *ប្រសិនបើលទ្ធផលតេស្តទាំងពីរលើកនៅតែផ្ទុយគ្នា ត្រូវចាត់ទុកថាលទ្ធផលមិនអាចកំណត់បាន ត្រូវបូមឈាមសារជាថ្មីដើម្បីធ្វើតេស្តសារឡើងវិញ ។*

## ៤.៤.៥.២ ការត្រួតពិនិត្យគុណភាព

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគនៃក្រសួងសុខាភិបាល ទទួលខុសត្រូវក្នុងការពិនិត្យគុណភាព នៃការធ្វើតេស្តរកមេរោគអេដស៍ ទាំងផ្នែកឯកជន និងសាធារណៈ ។

## ៤.៤.៥.១ ពិធីសារធ្វើតេស្តរកមេរោគអេដស៍

នៅប្រទេសកម្ពុជា ពិធីសារធ្វើតេស្តរកមេរោគអេដស៍ក្នុងសេវាផ្តល់ ប្រឹក្សា និងធ្វើតេស្តរកមេរោគអេដស៍ ដូចគ្នានឹងពិធីសារធ្វើតេស្តរកមេរោគអេដស៍ដើម្បីរករោគវិនិច្ឆ័យដែរ ។ ពិធីសារនៅក្នុងគោលការណ៍ណែនាំស្តីពីការផ្តល់ប្រឹក្សា និងការធ្វើតេស្តរកមេរោគបង្កជំងឺអេដស៍នេះ បានតាក់តែងរៀបចំ និងកែលំអរជាលំដាប់ដោយក្រសួងសុខាភិបាល ។

រាល់សេរ៉ូម រឺ ប្លូស្មាត្រូវធ្វើតេស្តលើកទីមួយដោយតេស្តធម្មតា រឺ តេស្តរហ័ស (Simple/ rapid assay):

- *សេរ៉ូមឈាមដែលគ្មានប្រតិកម្មក្នុងពេលធ្វើតេស្តលើកទី១ ត្រូវចាត់ទុកថាពុំមានអង្គបដិបក្ខប្រាណប្រឆាំងនឹងមេរោគអេដស៍*
- *សេរ៉ូមឈាមប្រតិកម្មក្នុងពេលធ្វើតេស្តលើកទីមួយ ត្រូវធ្វើតេស្តឡើងវិញម្តងទៀត ដោយប្រើប្រាស់តេស្តរហ័ស ឬធម្មតា (simple/rapid assay) ផ្សេងទៀត (ដែលខុសពីតេស្តទី១) រឺ ELISA*
- *សេរ៉ូមឈាមប្រតិកម្មក្នុងពេលធ្វើតេស្តទាំងពីរលើក ត្រូវចាត់ទុកថាមានអង្គបដិបក្ខប្រាណប្រឆាំងនឹងមេរោគអេដស៍*





- វាយតំលៃការយល់ដឹងរបស់អតិថិជន អំពីពតិមានទាក់ទងនឹងមេរោគអេដស៍ និងជំងឺអេដស៍
- ពិភាក្សា និងវាយតំលៃពីការប្រឈមមុខនឹងការឆ្លងមេរោគអេដស៍របស់អតិជន
- ពិភាក្សាអំពីជំរើសត្រឹមត្រូវ និងផែនការកាត់បន្ថយការប្រឈមមុខរបស់អតិថិជន
- ពន្យល់អតិថិជនអំពីអត្ថន័យ និងអ្វីៗដែលអាចកើតមានឡើងដោយសារលទ្ធផលវិជ្ជមាន អវិជ្ជមាន និងរយៈពេលចំហរ

## ៤.៤.៣ ការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តរកមេរោគអេដស៍ :

ការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្ត ធ្វើឡើងនៅពេលអតិថិជនមកទទួលលទ្ធផលតេស្ត ។ ហាមឃាត់ដាច់ខាតក្នុងការប្រាប់លទ្ធផលតេស្តដល់អតិថិជនតាមរយៈទូរស័ព្ទ តាមសំបុត្រ ឬដោយគ្មានការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្ត ។ ការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តសំដៅលើ :

**លទ្ធផលតេស្តអវិជ្ជមាន :**

- *បញ្ជាក់ប្រាប់លទ្ធផលតេស្ត និងពិភាក្សាអត្ថន័យតេស្តអវិជ្ជមាន និងអ្វីៗដែលកើតមានឡើងដោយសារលទ្ធផលតេស្ត ។*

- *ពិភាក្សាលទ្ធផលតេស្ត និងសង្ខេបផែនការកាត់បន្ថយការប្រឈមមុខរបស់អតិថិជន ដោយមានការគាំទ្រផ្លូវចិត្តពីអ្នកផ្តល់ប្រឹក្សា ។*

- *រៀបចំផែនការសំរាប់ធ្វើតេស្តម្តងទៀតតាមពេលវេលាសមស្រប ។*

**លទ្ធផលតេស្តវិជ្ជមាន :**

- *បញ្ជាក់ប្រាប់លទ្ធផល និងអត្ថន័យតេស្តវិជ្ជមាន ។*

- *ធានាអះអាងថា អតិថិជនមានលទ្ធភាពដោះស្រាយស្ថានភាពរបស់ខ្លួន ។*

- *ពិភាក្សាអំពីអារម្មណ៍ និងការរំជួលចិត្តរបស់អតិថិជន*

- *គាំទ្រផ្លូវចិត្តអតិថិជន*
- *ពិភាក្សាអំពីអ្វីៗដែលអាចកើតមានឡើងដល់អតិថិជន ដោយសារលទ្ធផលតេស្តរបស់គាត់*



គោលនយោបាយ យុទ្ធសាស្ត្រ និងគោលការណ៍ណែនាំស្តីពីការផ្តល់ប្រឹក្សានិងការធ្វើតេស្តរកមេរោគអេដស៍

- *ពិភាក្សាអំពីក្តីកង្វល់ និងការភ័យខ្លាចរបស់អតិថិជន*

- *ផ្តល់ប្រឹក្សាអំពីរបៀបដោះស្រាយបញ្ហាចំពោះមុខភ្លាមៗ និងជាក់ ស្តែង*

- *ផ្តល់ប្រឹក្សាអំពីការរស់នៅ និងដោះស្រាយរាល់បញ្ហាពាក់ព័ន្ធនឹងជំងឺ*

- *ផ្តល់ព៌តមានអំពីការថែរក្សាអោយមានសុខភាពល្អ*

- *ផ្តល់ព៌តមានស្តីពីសេវាថែទាំព្យាបាល សេវាផ្តល់ប្រឹក្សា សេវាឧបត្ថម្ភក្រុមគាំទ្រអ្នកជំងឺអេដស៍ និងប្រភពធនធានដ៏ទៃទៀតដែលអាចជួយដល់អតិថិជន ។*

### ៤.៤.៤ ការផ្តល់ប្រឹក្សាគាំទ្រ

ក្នុងករណីលទ្ធផលតេស្តវិជ្ជមាន ត្រូវមានការផ្តល់ប្រឹក្សាគាំទ្របន្តបន្ទាប់បន្ថែមទៀត ។ ការផ្តល់ប្រឹក្សាគាំទ្រមានសារៈសំខាន់ណាស់ក្នុងការជួយអតិថិជនអោយអាចដោះស្រាយនូវស្ថានភាព ផ្សេងៗបាន ។

### ៤.៤.៥ ពិធីសារធ្វើតេស្តរកមេរោគអេដស៍ :